**Cambodian Mekong University**
Is the university that cares for the value of education

# EC102(3 Credits): Understanding a Nation Economy

## Course Description and Goals

This course will introduce students to the basic concepts in macroeconomics. Economics is the study of choice. In every day life, we challenge many choices in which economics has universal application. Students will learn to use a simple demand and supply analysis to examine the impact of various macroeconomic policies on the economy. While the focus of the course is theory, you yet will be able to come across with some examples for real life helping you see the usefulness of macro theory. After the course, students would have a better understanding of macroeconomic issues, such as inflation, unemployment, fiscal policy and monetary policies, economic growth, and balance of payment.

## Course Requirements

### Materials:

The assigned textbook for this class is Douglas Mc Taggart, Christopher Findlay and Michael Parkin, Economics, 2nd Edition, Addison Wesley, 1996.

**Students are expected to complete assigned readings prior to their discussion in class. The class schedule and a list of the assigned readings follow the grading policy.**

**Supplementary Materials:** Other Economics books are recommended to read *but* not required for this course.

### Readings:

All students are expected to read the assigned chapters in the text or any material before class. The class schedule and a list of the assigned readings follow the grading policy. As the semester progresses, I will supplement more handouts that are to be read prior to every class or discussion. If you miss class some interesting things may also slip away. Students also have to read and research for their homework or assignments. Plan yourself and time carefully from the very beginning of the course before you countering read shocks or frightening.

### Contact hours and teaching methods:

EC102 course is full time and normally consists of 64 contact hours over the sixteen-week period, taking the form of 32 hours of lectures, 16 hours of terminology classes and 16 hours of tutorial classes.

- The lecture will occupy two hours per week and terminology classes conduct in one hour per week, in which all participants for this subject, of each session, attend on a course as a single group.
- Small class groups supplement lectures in which they are an opportunity to work through problem sets, case studies, presentation and/or discuss seminar papers.

# Grading Policy

Your course grade will be based on a total of 100 possible points:

| | |
|---|---|
| Classroom participation and attendance | (10%) |
| Assignment | (25%) |
| Quizzes | (10%) |
| Midterm Examination | (20%) |
| Final Examination | (35%) |

- Your final grade will be based on your performance in homework/ assignments, quizzes, class participation and exams.
- Please note the dates of the exams listed on the course outline. There will be no makeup exams. An unexcused absence from an exam will be counted as a failure for that exam. Two unexcused absences from exams will be counted as a failure for the course.
- There will be no extra credit assignments.
- The final exam takes the form of two-hour and closed book exam, unless otherwise specified by the instructor, in which will be held in week 18th. However the specific date for this exam will be notified later.
- The midterm exam will be held in one hour basis and in your regular class during the week 8.
- There will be periodic quizzes, which are in very two weeks. Quizzes will be announced one week in advance. The quizzes will be given at the end of the class and each quiz will take no more than 15 minutes. The quizzes will generally consist on multiple-choice questions.
- The lowest grade will not be considered for the computation of your final grade.
- Performance on these quizzes, as well as your contributions to daily dialogue in class, will be factored into your class participation grade. They will also be used to check class attendance.

# Course Outline and Schedule

| Week | Date | Topic | Reading Tasks | Comment |
|---|---|---|---|---|
| | | **Part 1: Introduction** | | |
| 1 | | Getting started & Demand and Supply | Handout | |
| | | **Part 2: MACROECONOMIC PERFORMANCE** | **(Chapter 21, 22, 23)** | |
| 2 | | Macroeconomic Challenges and Choices | Chapter 21 | Quiz 1 |

| | | | | |
|---|---|---|---|---|
| 3 | | Monitoring macroeconomic Performance | Chapter 22 | |
| 4 | | Aggregate Demand and Aggregate Supply | Chapter 23 | Quiz 2, HW 1 due |
| | | **Part 3: AGGREGATE DEMAND, SUPPLY AND INFLATION** | **(Chapter 24...29, 33)** | |
| 5 | | Expenditure Decisions and GDP | Chapter 24 | |
| 6 | | Aggregate Demand Multipliers Fiscal Policy | Chapter 25 | Quiz 3 |
| 7 | | Government and Fiscal Policy | Chapter 26 | |
| 8 | | Money Banking and the Interest Rates | Chapter 27 | Quiz 4 |
| 9 | | The Reserve Bank (Central Bank) and Monetary Policy | Chapter 28 | HW 2 due |
| 10 | | Fiscal Policy and Monetary Policy and Exchange Rate | Chapter 29 | Quiz 5 |
| 11 | | Unemployment and Short run Aggregate Supply | Chapter 32 | |
| 12 | | Inflation | Chapter 33 | Quiz 6, HW 3 due |
| | | **Part 4: MACROECONOMICS PROBLEMS, POLICIES AND TRADE** | **(Chapter 35, 37)** | |
| 13 | | Stabilizing the Economy | Chapter 35 | |
| 14 | | The Balance of Payments and the Dollar | Chapter37 | Quiz 7 |
| 15 | | Additional class for incomplete chapters and/or Student's presentations | To be advised | HW 4 due |
| 16 | | Chapter review and others | To be advised | Surprising quiz 8 |
| 17 | | Prepare for exams | * During this week we might have an addition class | |
| 18 | | **Final Exam** | * To be advised for date and time | |

# សាកលវិទ្យាល័យមេគង្គកម្ពុជា

ជាសាកលវិទ្យាល័យដែលយកចិត្តទុកដាក់ពីតំលៃនៃការអប់រំ

# EC102 (៣ ក្រេឌីត): ការយល់ដឹងពីសេដ្ឋកិច្ចនៃប្រទេសជាតិមួយ (ម៉ាក្រូសេដ្ឋកិច្ចវិទ្យា)

## គោលបំណង និង ការបរិយាយពីមុខវិជ្ជា :

មុខវិជ្ជានេះនឹងណែនាំចំពោះនិស្សិតដោយផ្តើមពីគោលគំនិតជាមូលដ្ឋាននៃម៉ាក្រូសេដ្ឋកិច្ច។ សេដ្ឋកិច្ចវិទ្យា គឺជាការសិក្សាអំពីជំរើស។ ក្នុងជីវភាពប្រចាំថ្ងៃ យើងប្រឈមមុខជាមួយជំរើសជាច្រើន ដែលក្នុងនោះមុខវិជ្ជាសេដ្ឋកិច្ច មានការអនុវត្តន៏ជាសកលលើបញ្ហាទាំងនេះ។ និស្សិតនឹងសិក្សាអំពីការវិភាគទៅការផ្គត់ផ្គង់និងតំរូវការសមញ្ញៗ ដើម្បីត្រួតពិនិត្យមើលឥទ្ធិពលនៃគោលនយោបាយសេដ្ឋកិច្ចនានា ទៅលើខឿនសេដ្ឋកិច្ចនៃប្រទេសណាមួយ។ ទន្ទឹមនឹងការសិក្សាក្នុងមេរៀននេះផ្តោតសំខាន់លើទ្រឹស្តី អ្នកនៅតែអាចជួបប្រទះនូវឧទាហរណ៏ខ្លះៗថែមទៀតពីជីវភាពជាក់ស្តែងដើម្បីជួយអ្នកអោយយល់ច្បាស់ពីសារៈប្រយោជន៏នៃទ្រឹស្តីម៉ាក្រូសេដ្ឋកិច្ច។ បន្ទាប់ពីរៀនចប់ និស្សិតនឹងយល់បានច្បាស់លាស់អំពី *បញ្ហាម៉ាក្រូសេដ្ឋកិច្ច ដូចជា អតិផរណា ភាពអត់ការងារធ្វើ គោលនយោបាយរូបិយវត្ថុ គោលនយោបាយសារពើពន្ធ ភាពរីកចំរើននៃសេដ្ឋកិច្ច និង តុល្យភាពជញ្ជីងទូទាត់។*

## គំរូវការរបស់មុខវិជ្ជា :

- ***ឯកសារ :*** សៀវភៅដែលតំរូវសំរាប់ការសិក្សាក្នុងថ្នាក់នេះគឺ Douglas Mc Taggart, Christopher Findlay and Michael Parkin, *Economics*, 2nd Edition, Addison Wesley, 1996.

សៀវភៅ សេដ្ឋកិច្ចដទៃទៀត គឺគួរតែអានបន្ថែម តែមិនតំរូវចាំបាច់សំរាប់ថ្នាក់នេះទេ។

- ***ការអាន :*** និស្សិតត្រូវអានជាមុននូវអត្ថបទ ឬ មេរៀនទាំងឡាយដែលបានកំណត់ មុនពេលពិភាក្សា ឬ សិក្សាក្នុងថ្នាក់ ។ កាលវិភាគសំរាប់មេរៀន និង បញ្ជីអត្ថបទ មេរៀនដែលត្រូវអាន គឺមានបង្ហាញជូននៅផ្នែកខាងក្រោម។ នៅពេលការសិក្សាក្នុងឆមាសដំណើរការ ខ្ញុំនឹងចែកជូនអត្ថបទបន្ថែមទៀត ដែលត្រូវតែអានមុនពេលចូលរៀនក្នុងថ្នាក់ ឬកិច្ចពិភាក្សាទាំងឡាយ។ បើអ្នកខកខានមិនបានចូលរៀនថ្នាក់ណា មួយនោះរឿងរ៉ាវល្អៗគួរចាប់អារម្មណ៏ ក៏បាត់បង់ផងដែរ។ និស្សិតក៏ត្រូវអាននិងស្រាវជ្រាវផងដែរសំរាប់កិច្ចការផ្ទះ និងកិច្ចស្រាវជ្រាវដែល

គ្រូប្រគល់អោយ។ ចូររៀបចំពេលវេលា និងផែនការអោយបានត្រឹមត្រូវហ្មត់ហ្មងសំរាប់ខ្លួនអ្នកផ្ទាល់ តាំងពេលចាប់ផ្តើមដំបូងទៅ ដើម្បីជៀសវាងការតក់ស្លុតនូវអ្វីដែលត្រូវអានមានច្រើនសំបើមមុនពេលប្រលង។

**ម៉ោងសិក្សា និង វិធីសាស្ត្របង្រៀន :**

មុខវិជ្ជាសេដ្ឋកិច្ច EC102 ត្រូវបង្រៀនក្នុងលក្ខណៈពេញម៉ោង ហើយ មាន៦៤ម៉ោងសិក្សា ក្នុងរយៈពេល១៦សប្តាហ៍ ដែលត្រូវជួបជាមួយនិស្សិត។ ការបង្រៀននេះត្រូវបានបែងចែកតាមរូបភាពបីយ៉ាងគឺ : *៣២ម៉ោងសំរាប់ថ្នាក់បឋកថា ១៦ម៉ោងសំរាប់ថ្នាក់ពិគ្រោះ ពិភាក្សាលើបញ្ហា ចំងល់ផ្សេងៗ ហើយនៅមានបន្ថែមម៉ោងចំនួន១៦ម៉ោងសិក្សាទៀត ដែលត្រូវបានរៀបចំឡើងដើម្បីបង្រៀនពាក្យបច្ចេកទេសគន្លឹះទាក់ទងនឹងមេរៀននិមួយៗនៃមុខវិជ្ជានេះ។*

- ម៉ោងបឋកថា គឺធ្វើឡើងក្នុងរយៈពេល ២ម៉ោងក្នុងមួយសប្តាហ៍ ហើយ ម៉ោងបង្រៀនពាក្យបច្ចេកទេសធ្វើក្នុងរយៈពេល១ម៉ោង ក្នុងមួយសប្តាហ៍។ និស្សិតដែលជ្រើសរើសមុខវិជ្ជានេះ សំរាប់វេនសិក្សានិមួយៗ ត្រូវចូលរៀនម៉ោងបឋកថា និងម៉ោងពាក្យបច្ចេកទេស ក្នុងថ្នាក់(ក្រុម)តែមួយរួមគ្នា។
- ចំនែកម៉ោងពិគ្រោះ ពិភាក្សា គឺជាក្រុមថ្នាក់តូចៗ ដែលរៀបចំបន្ថែមលើម៉ោងបឋកថា។ ក្នុងម៉ោងនេះ និស្សិតមានឱកាសសាកសួរដេញដោលជុំវិញបញ្ហាទាំងឡាយពួកគេមានលើខ្លឹមសារមេរៀន សំណួរនានា ។ល។ ហើយពេលនេះក៏ជាឱកាសដែលគ្រូបង្រៀននិងនិស្សិតរួមគ្នាដោះស្រាយបញ្ហា ចំលង់ផ្សេងៗ និង លើកចំណោទបញ្ហា វិភាគ ពិភាក្សា ផងដែរ។

**គោលការណ៍វាយតំលៃ :**

ការវាយតំលៃលើការសិក្សារបស់និស្សិតនឹងត្រូវកំណត់លើមូលដ្ឋានពិន្ទុសរុប ១០០ពិន្ទុ ដោយមានការបែងចែកដូចតទៅ:

| | |
|---|---|
| - វត្តមាននិងសកម្មភាពចូលរួមក្នុងថ្នាក់ | ១០% |
| - កិច្ចការស្រាវជ្រាវ-កិច្ចការផ្ទះ | ២៥% |
| - ប្រលងត្រួតពិនិត្យរយៈពេលខ្លី (Quiz) | ១០% |
| - ប្រលងត្រួតពិនិត្យ (Midterm Exam) | ២០% |
| - ប្រលងដំណាច់ឆមាស (Final Exam) | ៣៥% |
| សរុបពិន្ទុ | ១០០% |

- កាលបរិច្ឆេទនៃការប្រលងនានា និងកិច្ចការស្រាវជ្រាវ កិច្ចការផ្ទះផ្សេងៗ មានរាយនៅក្នុងតារាងខាងក្រោមនេះ។ គ្មានការប្រលងរៀបចំឡើងសំរាប់អ្នកដែលខកខានមិនបានប្រលងលើកទី១នោះទេ។ អវត្តមានគ្មានមូលហេតុនៃការប្រលងណាមួយ គឺនឹងចាត់ទុកជាបានធ្លាក់ ចំពោះការប្រលងនោះ។ អវត្តមានគ្មានមូលហេតុចំនួនពីរដង ពីការប្រលងនានា នឹងត្រូវចាត់ទុកថាបានធ្លាក់ចំពោះមុខវិជ្ជានេះ។
- គ្មានកិច្ចការស្រាវជ្រាវបន្ថែម ដើម្បីទទួលបានពិន្ទុបន្ថែមទេ។

- ការប្រលងដំណាច់ឆមាស (Final Exam)នឹងធ្វើឡើងក្នុងរយៈពេល២ម៉ោង ហើយរាល់ឯកសារផ្សេងៗមិនអនុញ្ញាតិ អោយប្រើទេ (បើគ្មានការណែនាំបន្ថែមពីគ្រូបង្រៀនមុខវិជ្ជានេះ)។ ការប្រលងនេះនឹងប្រព្រឹត្តទៅ ក្នុងអំឡុងសប្តាហ៍ទី១៨ តែកាលបរិច្ឆេទ ពេលវេលាជាក់ លាក់ នឹងជំរាបជូនពេលក្រោយ។
- ការប្រលងត្រួតពិនិត្យ (Midterm Exam)នឹងធ្វើឡើងរយៈពេល១ម៉ោងនៅក្នុងថ្នាក់រៀនធម្មតា ក្នុងអំឡុងសប្តាហ៍ទី៨ ។
- ការប្រលងត្រួតពិនិត្យរយៈពេលខ្លី (Quiz) នឹងធ្វើឡើងម្តងម្កាល ពោលគឺសឹងតែរៀងរាល់២សប្តាហ៍ម្តង។ ការប្រលងនេះនឹងជំរាបមុន១សប្តាហ៍ ហើយការប្រលង (ជាទូទៅ សំណួរជ្រើសចំលើយ)នឹងធ្វើនៅចុងម៉ោងសិក្សា ក្នុងរយៈពេលមិនច្រើនជាង ១៥នាទី ឡើយ។ ការប្រលងដែលទទួលបានពិន្ទុទាបបំផុតនឹងមិនរាប់បញ្ចូល ដើម្បីគណនាពិន្ទុសរុបចុងក្រោយរបស់អ្នកទេ។
- លទ្ធផលសំរេចបានពីការប្រលងត្រួតពិនិត្យរយៈពេលខ្លីទាំងនេះ ព្រមទាំងការចូលរួមចំនែកសកម្មភាពសាកសួរ សំណួរនានាក្នុងថ្នាក់ នឹងត្រូវរាប់បញ្ចូលសំរាប់ពិន្ទុ "វត្តមាននិងសកម្មភាពចូលរួមក្នុងថ្នាក់"។ ការប្រលងត្រួតពិនិត្យរយៈពេលខ្លីទាំងនេះ ក៏ត្រូវបានប្រើសំរាប់តាមដានវត្តមានក្នុងថ្នាក់ផងដែរ។

## ការបរិយាយ និង កាលវិភាគនៃមុខវិជ្ជា

| សប្តាហ៍ | ប្រធានបទ | មេរៀន អត្ថបទ ត្រូវអាន | កិច្ចការផ្សេងៗ |
|---|---|---|---|
| | **ផ្នែក ១ សេចក្តីផ្តើម** | | |
| ១ | សេចក្តីផ្តើម តំរូវការ និង ការផ្គត់ផ្គង់ | អត្ថបទបន្ថែម | |
| | **ផ្នែក ២ ស្ថាដៃនៃម៉ាក្រូសេដ្ឋកិច្ច** | **(មេរៀន ២១ ២២ ២៣)** | |
| ២ | ជំរើស និង ការប្រឈមមុខនៃម៉ាក្រូសេដ្ឋកិច្ច | មេរៀន ២១ | ត្រួតពិនិត្យរយៈពេលខ្លី ១ |
| ៣ | ការត្រួតពិនិត្យលើស្ថាដៃនៃម៉ាក្រូសេដ្ឋកិច្ច | មេរៀន ២២ | |
| ៤ | តំរូវការដុល និង ការផ្គត់ផ្គង់ដុល | មេរៀន ២៣ | ត្រួតពិនិត្យរយៈពេលខ្លី ២<br>ប្រគល់ កិច្ចការផ្ទះ ១ |
| | **ផ្នែក ៣ តំរូវការដុល ការផ្គត់ផ្គង់ដុល និង អតិផរណា** | **(មេរៀន ២៤...២៩ ៣៣)** | |
| ៥ | សេចក្តីសំរេចចិត្តពីការចំណាយ និង ផសស(GDP) | មេរៀន ២៤ | |
| ៦ | តំរូវការដុល មេគុណ គោលនយោបាយសារពើពន្ធ | មេរៀន ២៥ | ត្រួតពិនិត្យរយៈពេលខ្លី ៣ |
| ៧ | រដ្ឋាភិបាល និង គោលនយោបាយសារពើពន្ធ | មេរៀន ២៦ | |
| ៨ | រូបិយវត្ថុ ធនាគារ និង អត្រាការប្រាក់ | មេរៀន ២៧ | ត្រួតពិនិត្យរយៈពេលខ្លី ៤ |

| | | | |
|---|---|---|---|
| ៩ | ធនាគារកណ្ដាល និង គោលនយោបាយរូបិវត្ថុ | មេរៀន ២៨ | ប្រគល់ កិច្ចការផ្ទះ ២ |
| ១០ | គោលនយោបាយសារពើពន្ធ-រូបិយវត្ថុ និងអត្រាប្ដូរប្រាក់ | មេរៀន ២៩ | ត្រួតពិនិត្យរយៈពេលខ្លី ៥ |
| ១១ | ភាពអត់ការងារធ្វើ និង ការផ្គត់ផ្គង់រយៈពេលខ្លី | មេរៀន ៣២ | |
| ១២ | អតិផរណា | មេរៀន ៣៣ | ត្រួតពិនិត្យរយៈពេលខ្លី ៦<br>ប្រគល់ កិច្ចការផ្ទះ ៣ |
| | **ផ្នែក ៤ បញ្ហាម៉ាក្រូសេដ្ឋកិច្ច គោលនយោបាយ និង ពាណិជ្ជកម្ម** | **(មេរៀន ៣៥ ៣៧)** | |
| ១៣ | ការធ្វើអោយមានស្ថេរភាពសេដ្ឋកិច្ច | មេរៀន ៣៥ | |
| ១៤ | តុល្យភាពជញ្ជីងទូទាត់ និង រូបិយប័ណ្ណ (ដុល្លា) | មេរៀន ៣៧ | ត្រួតពិនិត្យរយៈពេលខ្លី ៧ |
| ១៥ | ថ្នាក់បន្ថែមម៉ោង ឬ បទបង្ហាញរបស់និស្សិត | នឹងជំរាបជូន | ប្រគល់ កិច្ចការផ្ទះ ៤ |
| ១៦ | កិច្ចការផ្សេងៗ និងរំលឹកមេរៀន | នឹងជំរាបជូន | ត្រួតពិនិត្យរយៈពេលខ្លី ៨ |
| ១៧ | ត្រៀមប្រលង | | (អាចមានថ្នាក់បន្ថែមម៉ោង) |
| ១៨ | **ប្រលងដំណាច់ឆមាស** | | (ជំរាបជូនកាលបរិច្ឆេទ និងពេលវេលា) |